01047541

E329

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 12 / 2014
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GIRAUD

**<u>ជនជាប់ចោទ</u>**

នួន ជា
ខៀវ សំផន

**<u>មេធាវីជនជាប់ចោទ</u>**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងផ្នែកចិត្តសាស្ត្រពីអ្នកជំនាញទៅលើជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលនូវការបញ្ជាក់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទណាម្នាក់មានការប្រែប្រួលគួរឱ្យកត់សម្គាល់នោះទេ ចាប់តាំងពីមានរបាយការណ៍របស់អ្នកជំនាញចុងក្រោយដែលបានដាក់នៅក្នុងខែ មីនា ឆ្នាំ ២០១៤នោះ[1]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យធ្វើការវាយតម្លៃនេះ ក្នុងគោលបំណងដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា នួន ជា និង ខៀវ សំផន នៅពេលបច្ចុប្បន្ននេះ នៅតែមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ និងដើម្បីវាយតម្លៃទៅលើសំណើសម្រាប់កំណត់កាលបរិច្ឆេទធ្វើសវនាការឱ្យបានសមស្រប។

## ២. សំអាងហេតុ

២. អង្គជំនុំជម្រះសាលាដំបូង តាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចចាត់តាំងអ្នកជំនាញដើម្បីធ្វើការពិនិត្យវាយតម្លៃសម្បទាផ្នែករាងកាយ និងផ្លូវចិត្តរបស់ជនជាប់ចោទ[2]។

៣. បច្ចុប្បន្ននេះ នួន ជា មានអាយុ ៨៨ ឆ្នាំ[3]។ នៅក្នុងអំឡុងពេលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្រនៅថ្ងៃទី ២៤ និង ២៥ ខែ មីនា ឆ្នាំ ២០១៤ អ្នកជំនាញផ្នែកវេជ្ជសាស្ត្របានរកឃើញថា នួន ជា មានសុខភាពល្អប្រសើរ និងមានស្មារតីល្អ បានជាសះស្បើយទាំងស្រុងពីជំងឺរលាកទងសួតកម្រិតធ្ងន់ធ្ងរ

---

[1] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ នួន ជា ឯកសារ E301/10/6 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ("របាយការណ៍អំពី នួន ជា")។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ ខៀវ សំផន ឯកសារ E301/10/7 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ("របាយការណ៍អំពី ខៀវ សំផន") ។

[2] វិធាន ៣១, ៣២ នៃវិធានផ្ទៃក្នុង។ សូមមើល ផងដែរ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម ឯកសារ E238/11/1 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៩។ សេចក្តីសម្រេចលើកទីពីរលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៣។

[3] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រមសំណុំរឿង ០០២/០១") កថាខណ្ឌ ៣០៥។

ក្នុងឆ្នាំ ២០១៣ និងអាចស្តាប់ឮបានល្អ[4]។ គាត់អាចឈរបាន ដោយប្រើដែកច្រត់ទប់ ដោយគ្មានការឈឺចុកចាប់ ឬបញ្ហាលំបាកអ្វីឡើយ ប៉ុន្តែគាត់ត្រូវការគេជួយគ្រាហ៍ឱ្យក្រោកឡើងពីគ្រែ និងដាក់ទម្រេតលើគ្រែក្រោយពេលក្រោកអង្គុយ[5]។ អ្នកជំនាញដែលបានពិនិត្យ នួន ជា យល់ឃើញថា សាច់ដុំ និងឆ្អឹងខ្នងរបស់គាត់ បង្ហាញនូវសញ្ញានៃការចុះខ្សោយទៅតាមអាយុ[6]។ ចក្ខុវិញ្ញាណរបស់គាត់ បានចុះខ្សោយ ដោយសារតែភ្នែកខាងឆ្វេងរបស់គាត់ឡើងបាយធ្ងន់ធ្ងរ ប៉ុន្តែគាត់អាចអានបាន ដោយប្រើប្រាស់វ៉ែនតាធម្មតា បន្ទាប់ពីគាត់បានទទួលការវះកាត់ភ្នែកឡើងបាយខាងស្តាំរួចហើយ[7]។ នួន ជា បានបញ្ជាក់ថា គាត់មានសុខភាពល្អប្រសើរជាងកាលពីគាត់ទទួលការពិនិត្យផ្នែកវេជ្ជ-សាស្ត្រកាលពីពេលមុន ហើយដោយសារគាត់បានទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការព្យាបាលដោយចលនារាងកាយនោះ ឥឡូវនេះគាត់អាចដើរបាន[8]។ របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ បានសន្និដ្ឋានថា យោងទៅលើសមត្ថភាពផ្សេងៗ ដែលបានកំណត់នៅក្នុងរឿងក្តី *Strugar*[9] នួន ជា ពុំមានបញ្ហាផ្លូវចិត្ត និងផ្លូវកាយ ដែលប៉ះពាល់ដល់សម្បទារបស់គាត់ ក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ និងចូលរួមក្នុងសវនាការឡើយ[10]។ នៅក្នុងរបាយការណ៍នេះ អ្នកជំនាញបានណែនាំឱ្យធ្វើការពិនិត្យមុខងារបញ្ញាស្មារតីរបស់ នួន ជា

---

[4] របាយការណ៍អំពី នួន ជា កថាខណ្ឌ ១១។

[5] របាយការណ៍អំពី នួន ជា កថាខណ្ឌ ១១។

[6] របាយការណ៍អំពី នួន ជា កថាខណ្ឌ ១១។

[7] របាយការណ៍អំពី នួន ជា កថាខណ្ឌ ១១។

[8] របាយការណ៍អំពី នួន ជា កថាខណ្ឌ ១០។

[9] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Strugar* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY សំណុំរឿងលេខ(IT-01-42-A) សាលដីកា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ ("សំណុំរឿង *Strugar*") កថាខណ្ឌ៥៥: "[...] បទដ្ឋានជាធរមានមានន័យថាជាការចូលរួមដែលអនុញ្ញាតឱ្យជនជាប់ចោទអនុវត្តសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ក្នុងវិសាលភាពដែលរូបគាត់អាចចូលរួមយ៉ាងមានប្រសិទ្ធភាពនៅក្នុងការជំនុំជម្រះក្តីនេះ និងមានការយល់ដឹងអំពីសារៈសំខាន់នៃកិច្ចដំណើរការនីតិវិធីនានា។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានត្រឹមត្រូវ ដូចដែលបានបង្ហាញតាមរយៈសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការជម្រះក្តីត្រូវអាស្រ័យលើបញ្ហាថាតើគាត់មានសមត្ថភាព "ធ្វើការពិនិត្យជារួម និងក្នុងលក្ខណៈសមស្រប និងដោយសុភវិនិច្ឆ័យ នៅកម្រិតដែលថា វាអាចទៅរួចសម្រាប់ជនជាប់ចោទក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនានា (ពេលខ្លះដោយមានជំនួយ) និងអនុវត្តសិទ្ធដែលត្រូវបានកំណត់បានគ្រប់គ្រាន់")។

[10] របាយការណ៍អំពី នួន ជា កថាខណ្ឌ ៤៣។

ជាទៀងទាត់ ជាពិសេស ប្រសិនបើឃើញថាមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ផ្នែកការចងចាំ និងមុខងារបញ្ញាស្មារតីរបស់គាត់[11]។

៤. បច្ចុប្បន្ននេះ ខៀវ សំផន មានអាយុ ៨៣ ឆ្នាំ[12]។ ចាប់តាំងពីឆ្នាំ ២០០៦ មក គាត់ត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺប្រគ្រីវ លើសឈាម និងរលាកផ្លូវដង្ហើមពីរលើក ដែលតម្រូវឱ្យមានការព្យាបាល[13]។ គាត់បានទទួលការវះកាត់ភ្នែកឡើងបាយទាំងសងខាងរបស់គាត់ និងអាចអានបានដោយប្រើកែវពង្រីក[14]។ នៅក្នុងអំឡុងពេលនៃការពិនិត្យរបស់អ្នកជំនាញ ខៀវ សំផន អាចដើរបាននៅជុំវិញបន្ទប់របស់គាត់ ដោយមិនចាំបាច់មានការជួយឡើយ[15]។ គាត់ធ្លាប់មានប្រវត្តិឧប្បទ្ទវហេតុជំងឺសរសៃឈាមខួរក្បាលពីរលើក ដែលតាំងពីពេលនោះមក គាត់បានជាសះស្បើយហើយ[16]។ ដោយសារតែគាត់ធ្លាប់មានជំងឺដាច់សរសៃឈាមក្នុងខួរក្បាលពីមុន ដូច្នេះគាត់មានការប្រឈមខ្ពស់នឹងបញ្ហាដាច់សរសៃឈាមក្នុងខួរក្បាលម្តងទៀត[17]។ វេជ្ជបណ្ឌិតម្នាក់ដែលបានស្គាល់ ខៀវ សំផន រយៈពេលពីរឆ្នាំ គិតមកត្រឹមពេលនោះ បានពន្យល់ថា ការផ្តោតអារម្មណ៍របស់គាត់ល្អ បើប្រៀបធៀបនឹងអ្នកដែលមានអាយុស្មើគាត់ ហើយអារម្មណ៍របស់គាត់មានភាពធម្មតា[18]។ របាយការណ៍នេះបានសន្និដ្ឋានថា ខៀវ សំផន ហាក់មានសុខភាពល្អ ទោះបីជាគាត់មានបញ្ហាសុខភាពមួយចំនួនយ៉ាងណាក្តី និងអាចធ្វើការបំលាស់ទី និងមើលថែទាំខ្លួនដោយខ្លួនឯងបាន[19]។ របាយការណ៍នេះ ក៏បានសន្និដ្ឋានផងដែរថា ពុំមានបញ្ហាសុខភាពផ្លូវកាយ ដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់គាត់ក្នុងការចូលរួមសវនាការឡើយ[20]។ ចាប់តាំងពីមានរបាយការណ៍នេះមក ខៀវ សំផន បានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យចំនួនពីរលើក គឺលើកទីមួយមានរយៈពេល ០៦ ថ្ងៃ កាលពីខែ

---

[11] របាយការណ៍អំពី នួន ជា កថាខណ្ឌ ៤៤។

[12] សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥១។

[13] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៦។

[14] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៦, ១១។

[15] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ១០។

[16] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ១៧។

[17] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ១៥។

[18] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ១៨។

[19] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៣៦។

[20] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៣៩។

ឧសភា ឆ្នាំ ២០១៤ ដោយមានរោគសញ្ញាគ្រុនផ្តាសាយ[21] និងលើកទីពីរ កាលពីខែ កញ្ញា ឆ្នាំ ២០១៤ ដោយមូលហេតុជំងឺថប់ដង្ហើមស្រួចស្រាល និងគ្រុនក្តៅខ្លាំង[22]។ លិខិតអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យទាំងពីរនេះបញ្ជាក់ថា ស្ថានភាពសុខភាពរបស់គាត់ មានលក្ខណៈធូរស្រាល[23]។ ដូចគ្នាជាមួយ នួន ជា ដែរ អ្នកជំនាញដែលបានពិនិត្យគាត់ បានណែនាំឱ្យធ្វើការពិនិត្យមុខងារបញ្ញាស្មារតីរបស់ ខៀវ សំផន ជាទៀងទាត់ ជាពិសេស ប្រសិនបើរកឃើញថាមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ផ្នែកការចងចាំ និងមុខងារបញ្ញាស្មារតីរបស់គាត់[24]។

៥. អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាជាការសមស្រប និងចាំបាច់ក្នុងការពិនិត្យវាយតម្លៃឡើងវិញលើសម្បទារបស់ជនជាប់ចោទ ដោយពិចារណាទៅលើវ័យចាស់ និងស្ថានភាពសុខភាព ចំពោះមុខរបស់ពួកគាត់ រយៈពេលដែលអ្នកជំនាញបានធ្វើការពិនិត្យវាយតម្លៃលើកចុងក្រោយទៅលើសម្បទារបស់ពួកគាត់ និងតម្រូវការឱ្យមានការចូលរួមពីជនជាប់ចោទនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងពេលឆាប់ៗខាងមុខនេះ។

## ៣. ការចាត់តាំងអ្នកជំនាញ និងសេចក្តីបង្គាប់

៦. អង្គជំនុំជម្រះសាលាដំបូងសម្រេចចាត់តាំងវេជ្ជបណ្ឌិតជំនាញខាងព្យាបាលថែទាំជំងឺមនុស្សចាស់ វេជ្ជបណ្ឌិត CHAN Kin Ming និងអ្នកជំនាញផ្នែកវិកលវិទ្យា វេជ្ជបណ្ឌិត ហួត លីនណា ("ជារួមហៅថា "អ្នកជំនាញ") ដើម្បីពិនិត្យវាយតម្លៃលើ នួន ជា និង ខៀវ សំផន និងសហការគ្នាដើម្បីផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូងនូវព័ត៌មានដូចបានបញ្ជាក់ខាងក្រោម[25]។ ជាដំបូង អ្នកជំនាញត្រូវ

---

[21] របាយការណ៍វេជ្ជសាស្ត្ររបស់ ខៀវ សំផន ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ E13/179/1 ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៤។ លិខិតអនុញ្ញាតឱ្យ ខៀវ សំផន ចេញពីមន្ទីរពេទ្យ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ E13/179/1.3 ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤។

[22] របាយការណ៍វេជ្ជសាស្ត្ររបស់ ខៀវ សំផន ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ E13/199/1 ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៤។

[23] ប័ណ្ណអនុញ្ញាតឱ្យ ខៀវ សំផន ចេញពីមន្ទីរពេទ្យ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ E13/179/1.3 ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤។ ប័ណ្ណអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យ – ខៀវ សំផន ឯកសារ E13/200/5 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤។

[24] របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៤២៤។

[25] អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចពីមុនថា ទាំងវេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លីនណា គឺជាអ្នកជំនាញដែលមានគុណវុឌ្ឍិ។ *សូមមើល* សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងដីកាចាត់តាំងអ្នកជំនាញ ឯកសារ E301/10 ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ១០។

ធ្វើសម្បថជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខា ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងដោយភាពស្មោះត្រង់ ដោយសម្ងាត់ និងអស់ពីលទ្ធភាព។ បន្ទាប់ពីពិនិត្យវាយតម្លៃលើជនជាប់ចោទរួច អ្នកជំនាញត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយអំពីការរកឃើញរបស់ខ្លួនចំពោះជនជាប់ចោទម្នាក់ៗ។ របាយការណ៍នីមួយៗ ត្រូវរួមបញ្ចូលនូវសេចក្តីបញ្ជាក់របស់អ្នកជំនាញថា អ្នកជំនាញបានបញ្ចប់ការពិនិត្យវាយតម្លៃជារួម ឬជាបុគ្គល និងបានធ្វើរបាយការណ៍រួចរាល់ហើយ។ អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឱ្យអ្នកជំនាញធ្វើការទំនាក់ទំនងជាមួយនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន សម្រាប់គោលបំណងនេះ។

៧. របាយការណ៍របស់អ្នកជំនាញ ត្រូវរួមបញ្ចូលនូវព័ត៌មាន ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដែលបានពិពណ៌នានៅក្នុងរឿងក្តី *Strugar* ដែលនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថាតើ ជនជាប់ចោទម្នាក់ៗមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរ ឬទេ។ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការធានានូវការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនជាប់-ចោទទាំងពីរ នួន ជា និង ខៀវ សំផន នៅក្នុងដំណើរការសវនាការរបស់ពួកគាត់នោះ អ្នកជំនាញក៏ត្រូវធ្វើការវាយតម្លៃ និងធ្វើរបាយការណ៍ផងដែរអំពីថាតើ ការសម្របសម្រួលដែលបានផ្តល់ជូនរួមទាំងឧបករណ៍សោតទស្សន៍ និងការកំណត់រយៈពេលសម្រាប់ចូលរួមក្នុងសវនាការ ឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងបញ្ហាសុខភាពជាក់ស្តែងរបស់ជនជាប់ចោទម្នាក់ៗដែរ ឬទេ។

៨. អនុលោមតាមភារកិច្ចនេះ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ថា អ្នកជំនាញត្រូវ៖

(ក) ពិនិត្យនូវរាល់របាយការណ៍ជំនាញ និងរបាយការណ៍វេជ្ជសាស្ត្រដែលពាក់ព័ន្ធទាំងអស់ និងសម្ភារៈនានាដែលមាននៅក្នុងសំណុំរឿងក្នុងពេលបច្ចុប្បន្ន ឬយោងលើសម្ភារៈនានាដែលមានក្នុងសំណុំរឿងនោះ ឬដែលត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ឬមន្ទីរពេទ្យផ្សេងទៀត។

(ខ) ពិនិត្យជនជាប់ចោទម្នាក់ៗ ក្នុងគោលបំណងដើម្បីកំណត់នូវកម្រិតសុខភាពផ្លូវកាយ និងបញ្ហាស្មារតីរបស់គាត់ ក៏ដូចជាការវិនិច្ឆ័យទៅលើស្ថានភាពសុខភាព និងបញ្ហាស្មារតីរបស់ជនជាប់ចោទម្នាក់ៗ និងភាពល្អប្រសើរឡើង ឬភាពចុះដុនដាបនៃស្ថានភាពទាំងនេះចាប់តាំងពីមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងបញ្ហាស្មារតីរបស់ជនជាប់ចោទ កាលពីពេលថ្មីៗកន្លងទៅនេះ។

(គ) ធ្វើការពិគ្រោះយោបល់តាមការចាំបាច់ ជាមួយអ្នកជំនាញវេជ្ជសាស្ត្រ និងអ្នកជំនាញជំងឺផ្លូវចិត្តផ្សេងទៀត ដែលបានធ្វើរបាយការណ៍ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត

កាលពីលើកមុន អំពីស្ថានភាពរបស់ជនជាប់ចោទ ឬជាមួយវេជ្ជបណ្ឌិតដែលធ្លាប់បានព្យាបាលជំងឺរបស់ជនជាប់ចោទម្នាក់ៗ ឬពិនិត្យបញ្ហាផ្សេងៗទៀត ក្នុងអំឡុងពេលដែលពួកគាត់ស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក។

(ឃ) បង្ហាញនៅក្នុងរបាយការណ៍របស់ខ្លួនអំពី ការវិនិច្ឆ័យណាមួយ និងការវិនិច្ឆ័យបន្ថែមទៀតទាំងអស់ ដែលត្រូវបានបង្គាប់ដោយអ្នកជំនាញ ប៉ុន្តែត្រូវបានធ្វើឡើងដោយបុគ្គលផ្សេងទៀត រួមជាមួយនឹងអត្តសញ្ញាណរបស់បុគ្គលទាំងនោះ។

(ង) ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីលទ្ធផលនៃការពិនិត្យ និងការពិគ្រោះយោបល់ពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ៗ។

៩. អ្នកជំនាញត្រូវចាត់ថ្នាក់ការងាររបស់ខ្លួនថាជាការងារសម្ងាត់ ដូចជាការរក្សាការសម្ងាត់រវាងគ្រូពេទ្យ និងអ្នកជំងឺ និងមិនត្រូវលាតត្រដាងព័ត៌មានណាមួយ ស្តីអំពីការពិនិត្យវាយតម្លៃ ឬការវិនិច្ឆ័យរបស់ខ្លួនទៅលើជនជាប់ចោទ ឬរបាយការណ៍របស់ខ្លួនអំពីបញ្ហានេះឡើយ លើកលែងតែការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង ឬជូនអ្នកជំនាញដែលទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈពេទ្យផ្សេងទៀតនៅក្នុងអំឡុងពេលធ្វើការវិនិច្ឆ័យទាំងឡាយ ដែលបានយោងនៅក្នុង កថាខណ្ឌ ៨ (គ) *ខាងលើ*។ អ្នកជំនាញ ត្រូវមានអ្នកបកប្រែភាសាដើម្បីជួយដល់ពួកគាត់ ព្រមទាំងជំនួយការខ្មែរដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈពេទ្យ ដែលពួកគាត់ទាំងនោះក៏មានកាតព្វកិច្ចគោរពភាពសម្ងាត់នៃការត្រួតពិនិត្យ និងរបាយការណ៍ផងដែរ។

១០. ក្រៅពីនេះ អ្នកជំនាញត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយបទប្បញ្ញត្តិជាធរមានទាំងអស់ នៃវិធាន ៣១ និងវិធាន ៣២ នៃវិធានផ្ទៃក្នុង។

១១. តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងផ្នែកគ្រប់គ្រងតុលាការ អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ជូនអ្នកជំនាញនូវរាល់ឯកសារសម្ងាត់ផ្នែកវេជ្ជសាស្ត្រដែលពាក់ព័ន្ធទាំងអស់ ដែលមាននៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ននេះ។

**ផ្អែកនៅលើហេតុផលដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**ចាត់តាំង** វេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លីនណា ដើម្បីពិនិត្យវាយតម្លៃ នួន ជា និង ខៀវ សំផន អនុលោមតាមដីកានេះ។

01047548

002/19-09-2007-ECCC/TC

E329

**ជូនដំណឹង** ដល់គ្រប់ភាគីថា ការពិនិត្យជនជាប់ចោទ នឹងត្រូវចាប់ផ្តើមនៅថ្ងៃទី ១៩ និង ២០ ខែ មករា ឆ្នាំ ២០១៥ ហើយរបាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់ជនជាប់ចោទម្នាក់ៗ ជាភាសាអង់គ្លេស នឹងត្រូវបញ្ចប់ជាស្ថាពរនៅត្រឹមថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ និងសំណៅបកប្រែជាភាសាផ្លូវការនៃរបាយ-ការណ៍នោះ នឹងត្រូវផ្តល់ទៅឱ្យមេធាវីជនជាប់ចោទ នៅត្រឹមថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

**កំណត់កាលបរិច្ឆេទ** សវនាការលើសម្បទារបស់ជនជាប់ចោទនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ដើម្បីអនុញ្ញាតឱ្យអ្នកជំនាញបង្ហាញពីការយល់ឃើញរបស់ខ្លួន និងដើម្បីឱ្យមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា សួរសំណួរដល់អ្នកជំនាញ។ និង

**ស្នើសុំ** ឱ្យការិយាល័យរដ្ឋបាលរបស់ អ.វ.ត.ក និងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ផ្តល់នូវជំនួយចាំបាច់ទាំងអស់ដល់អ្នកជំនាញ សម្រាប់រយៈពេលនៃការបំពេញភារកិច្ចរបស់ពួកគាត់។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * CHAMBRE DE PREMIÈRE INSTANCE * E.C.C.C * C.E.T.C

**និល ណុន**